ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមហ៊ុនមេធាវី តម្រាច្បាប់
LEGAL CODE LAW FIRM
លេខ: ១២៤/ត.រ.ច/២១

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបើកដំណើរការផ្តល់សេវាកម្មច្បាប់ដោយផ្ទាល់ឡើងវិញ របស់ក្រុមហ៊ុនមេធាវី តម្រាច្បាប់

**យោង** ៖ -សេចក្តីសម្រេច លេខ: **១០០/២១ សសរ** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ របស់រដ្ឋបាលរាជធានីភ្នំពេញ ។

តបតាមយោងខាងលើ **ក្រុមហ៊ុនមេធាវី តម្រាច្បាប់** សូមជម្រាបជូនដំណឹងដល់សាធារណជន ក្រុមហ៊ុនជាដៃគូ អតិថិជន និងស្ថាប័នពាក់ព័ន្ធមេត្តាជ្រាបថា៖ ក្រោយការបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ចាប់ពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ នេះតទៅ ក្រុមហ៊ុនយើងខ្ញុំសម្រេចបើកដំណើរការបំពេញការងារដោយផ្ទាល់នៅក្នុងក្រុមហ៊ុនជាប្រក្រតីឡើងវិញ ដោយអនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអតិថិជន ។ ប៉ុន្តែ នៅក្នុងការប្រាស្រ័យទាក់ទងដោយផ្ទាល់នៅក្នុងការផ្តល់សេវាកម្មផ្នែកច្បាប់ ដោយ**ក្រុមហ៊ុនមេធាវី តម្រាច្បាប់** នេះ គឺក្រុមហ៊ុនយើងខ្ញុំនៅតែបន្តអនុវត្ត និង រឹតបន្តឹងបន្ថែមនូវវិធានការសុខាភិបាល "**៣ ការពារ ៣ កុំ**" យ៉ាងម៉ឺងម៉ាត់ និង តឹងរឹងបំផុត រួមទាំងវិធានការសុវត្ថិភាពផ្សេងទៀតតាមការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបញ្ចៀស និង ទប់ស្កាត់នូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បន្តទៀត ។

ទន្ទឹមនឹងនេះ ការងារផ្សេងទៀត ដែលមានភាពងាយស្រួល និង អំណោយផលនៅក្នុងការប្រតិបត្តិការការងារតាមរយៈប្រព័ន្ធអេឡិចត្រូនិក (Online) នោះ គឺក្រុមហ៊ុនយើងខ្ញុំនៅតែបន្តអនុវត្តការងារតាមបែបផែននេះជាអាទិភាពដដែល ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ក្រុមហ៊ុនជាដៃគូ អតិថិជន និងស្ថាប័នពាក់ព័ន្ធមេត្តាជ្រាបជាព័ត៌មាន និង ចូលរួមអនុវត្តនូវសេចក្តីសម្រេច លេខ: **១០០/២១ សសរ** របស់រដ្ឋបាលរាជធានីភ្នំពេញ ដូចយោងខាងលើ ដើម្បីប្រយុទ្ធប្រឆាំង ការពារការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ថ្ងៃព្រហស្បតិ៍ ១០ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១
**ក្រុមហ៊ុនមេធាវី តម្រាច្បាប់**